**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះវិហារ**
សំណុំរឿងព្រហ្មទណ្ឌលេខ:២១៤
ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១
ជំនុំជម្រះលេខ:២៧៣
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១

# សាលក្រម

លេខ:១(គ)
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ

*សាលាដំបូងខេត្តព្រះវិហារ*

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តព្រះវិហារ នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង០៨និង៣០នាទី ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ**

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] វុត្ថា និងឈ្មោះ [redacted] ជឿន ហៅ អាជឿន។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:២១៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១/.ឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ២៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរនគរបាលប្រចាំការនៅប្រាសាទព្រះវិហារ កម្រិតវប្បធម៌ថ្នាក់ទី១២ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្នភូ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ធី "រ" ម្តាយឈ្មោះ [redacted] ពៅ "រ" នៅលីវប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ជាប់ចោទពីបទ៖ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ .៥ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ (ឃុំខ្លួនថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១)

២/.ឈ្មោះ [redacted] គង្គារ ភេទស្រី អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករ កម្រិតវប្បធម៌ថ្នាក់ទី៤ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ធំ មានទីលំនៅបច្ចុប្បន្នភូមិ...

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ក្រឡាបញ្ជី
[redacted]

ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឪពុកឈ្មោះ[redacted]ធី "ស" ម្តាយឈ្មោះ [redacted]ចាន់ធី "ស" មេម៉ាយ មានកូនចំនួន០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ជាប់ចោទពីបទ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។(**ឃុំខ្លួនថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១**)

៣/.ឈ្មោះ[redacted]ជឿន ហៅ អាជឿន ភេទប្រុស កើតថ្ងៃទី០៤.០៨.២០០៦ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តព្រះវិហារ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ[redacted] ជា (រ) ម្តាយឈ្មោះ[redacted]រីម (រ) ជាអនីតិជន។(ក្រៅឃុំ)

៤/.ឈ្មោះ[redacted] ស៊ិនលី ហៅ អាលី ភេទប្រុស កើតថ្ងៃទី១៧.០៧.២០០០ ជនជាតិខ្មែរ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ហាត (រ) ម្តាយឈ្មោះ [redacted]គន្ធា (រ) នៅលីវ ជានីតិជន។(ក្រៅឃុំ)

ជាប់ចោទពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុមានដូចតទៅ៖

-កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៥ និង៣០នាទី នៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៅចំណុចជិតក្លោងទ្វារសណ្ឋាគារព្រះវិហារពេជ្រ កម្លាំងសមត្ថកិច្ចនៃប៉ុស្តិ៍រដ្ឋបាលឃុំស្រអែម និងឃុំកន្ទួត បានធ្វើការឃាត់ជនសង្ស័យម្នាក់ឈ្មោះ[redacted] គង្គារ ភេទស្រី អាយុ២១ឆ្នាំ រួមជាមួយថ្នាំញៀនមួយកញ្ចប់ប្រភេទមេតំហ្វេតាមីនទម្ងន់២,៧០ក្រាម ហើយធ្វើតេស្តនៅក្នុងទឹកនោមរបស់ឈ្មោះ[redacted]គង្គារ លទ្ធផលវិជ្ជមាន។ ឈ្មោះ [redacted] គង្គារ បានឆ្លើយថា ថ្នាំញៀននោះ ខ្លួនទិញពីឈ្មោះ[redacted] វុត្ថា តម្លៃ១០ម៉ឺនរៀល ហើយនៅថ្ងៃដដែល នៅវេលាម៉ោង១៩ និង២០នាទី សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យម្នាក់ទៀតឈ្មោះ [redacted] វុត្ថា រួមទាំងថ្នាំញៀនប្រភេទមេតំហ្វេតាមីនទម្ងន់៤៨,៥៨ក្រាម នៅភូមិចំបក់សែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ឈ្មោះ[redacted] វុត្ថា បានឆ្លើយថាគ្រឿងញៀននោះខ្លួនបានទិញពីឈ្មោះ ណាក់ បានចំនួន០៤ដង និងបានលក់ចែកចាយឱ្យឈ្មោះ លី, ឈ្មោះ ជឿន, ឈ្មោះ ហួរ និងឈ្មោះ[redacted]គង្គារ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៖១២៩៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ។

-បានឃើញដីកាដំណោះស្រាយលេខ៖២៩១៦ ព្រ/ទ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះវិហារ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ៖៧៥៧/២០២១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយសាក្សី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## **សំអាងហេតុ**

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] វុត្ថា នាពេលសវនាការ បានឆ្លើយថា កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា០៧យប់ សមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំនៅជិតសាលារៀនលេខ៨ ស្ថិតនៅភូមិចំបក់សែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ចំពោះមូលហេតុដែលសមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំ ដោយសារតែខ្លួនបានរក្សាទុកនូវថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ចំនួន០៣កញ្ចប់តូច និង០១កញ្ចប់ធំទម្ងន់សរុប៤៨,៥៨ក្រាម និងធ្វើតេស្តទឹកនោមមានសារធាតុញៀន។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រហែល១ឆ្នាំជាងហើយ និងចេះទិញថ្នាំញៀនយកមកលក់បន្តប្រហែលពីរបីខែនេះទេ។ ខ្លួនធ្លាប់ទិញថ្នាំញៀននេះពីឈ្មោះ **ណាក់** តែម្នាក់ប៉ុណ្ណោះ ដោយទិញចំនួន០៤ដងហើយ លើកទី១. តម្លៃ៦០ម៉ឺនរៀល, លើកទី២. តម្លៃ៨០ម៉ឺនរៀល, លើកទី៣. តម្លៃ១២០ម៉ឺនរៀល និងលើកទី៤. តម្លៃ០២លានរៀល(ទិញបានហើយសមត្ថកិច្ចឃាត់ខ្លួនតែម្តង)។ ថ្នាំញៀនដែលខ្លួនទិញបានកន្លងមក គឺខ្លួនបានយកលក់បន្តផង និងប្រើប្រាស់ខ្លួនឯងផង។ កន្លងមកខ្លួនធ្លាប់លក់ថ្នាំញៀនឲ្យទៅឈ្មោះ **លី** ភេទប្រុស អាយុប្រហែល២០ឆ្នាំ កម្ពស់ប្រហែល១.៥០ម៉ែត្រ សម្បុរខ្មៅស្រអែម សក់ត្រង់ រស់នៅក្រោយផ្សារស្រអែម ស្ថិតនៅភូមិ(មិនស្គាល់) ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ (ចំនួន០៣ដង ម្តង៤០ម៉ឺនរៀល), ឈ្មោះ **ជឿន** ភេទប្រុស អាយុប្រហែល២១ឆ្នាំ កម្ពស់ប្រហែល១.៥០ម៉ែត្រ សម្បុរខ្មៅស្រអែម សក់រួញ រស់នៅក្រោយសណ្ឋាគារព្រះវិហារពេជ្រ ស្ថិតនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ (ចំនួន០៣ដង ម្តង៤ម៉ឺនរៀល), ឈ្មោះ **ហួរ** ភេទប្រុស អាយុប្រហែល២៤ឆ្នាំ កម្ពស់ប្រហែល ១.៧០ម៉ែត្រ សម្បុរស សក់ត្រង់ រស់នៅម្តុំអង្គការអេដស៍ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ (ចំនួន០៣ដង ម្តង៤ម៉ឺនរៀល) និងឈ្មោះ **គង្គារ** (ចាប់ខ្លួនមកជាមួយ) ចំនួន០២ដង ក្នុងម្តងតម្លៃ១០ម៉ឺនរៀល។ ចំណែកឯឈ្មោះ **ណាក់** ភេទប្រុស អាយុប្រហែលជា៣០ឆ្នាំ សម្បុរខ្មៅស្រអែម កម្ពស់ប្រហែល១.៦០ម៉ែត្រ មាឌធំរស់នៅប្រាសាទ ១០ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ចម្លើយសារភាពរបស់ជនជាប់ចោទគឺជាភស្តុតាងមានលក្ខណៈត្រឹមត្រូវអាចឲ្យតុលាការពិចារណាបាន។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] គង្គារ នាពេលសវនាការ បានឆ្លើយថា កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា០៣រសៀល សមត្ថកិច្ចបានឃាត់រូបខ្លួននៅមុខក្លោងទ្វារសណ្ឋាគារព្រះវិហារពេជ្រ ស្ថិតនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ មូលហេតុដែលសមត្ថកិច្ចបានឃាត់រូបខ្លួនដោយសារតែ ខ្លួនបានរក្សាទុកនូវថ្នាំញៀនចំនួន០១កញ្ចប់តូចទម្ងន់២,៦៧ក្រាម។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រហែល៦ខែហើយ និងប្រើប្រាស់បានប្រហែល៦ដង ខ្លួនមិនដែលលក់ថ្នាំញៀនឲ្យអ្នកណាទេ គឺខ្លួនចេះតែប្រើប្រាស់តែប៉ុណ្ណោះ ខ្លួនចេះប្រើប្រាស់ថ្នាំញៀននេះ តាំងពីពេលដែលខ្លួនពិបាកចិត្តរឿងម៉ាក់ស្លាប់ និងចេះពីមិត្តភក្តិឈ្មោះ សុខា ភេទប្រុស អាយុប្រហែល១៩ឆ្នាំ រស់នៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ (ម្នាក់នេះមិនធ្លាប់លក់ថ្នាំញៀនទេ) សម្បុរខ្មៅ ខ្ពស់ សក់ខ្លីត្រង់។ ខ្លួនធ្លាប់ទិញថ្នាំញៀននេះ [illegible] ឈ្មោះ

[redacted] វុត្ថា រស់នៅភូមិចំបក់សែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ (ម្នាក់ចាប់ខ្លួនមកជាមួយខ្លួន) ចំនួន០៤លើក លើកទី១តម្លៃ១០ដុល្លារ, លើកទី២អស់៣ម៉ឺនរៀល, លើកទី៣ តម្លៃ៤ម៉ឺនរៀល និងលើកទី៤ តម្លៃ១០ម៉ឺនរៀល (ទិញបានហើយប៉ូលិសចាប់ខ្លួនតែម្តង)។ ខ្លួនសូមឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនផង ព្រោះខ្លួនមានកូនតូចអាយុទើប២ឆ្នាំត្រូវមើលថែរក្សា សព្វថ្ងៃកូនរបស់ខ្លួនផ្ញើនឹងបងប្រុសជួយមើលថែ។ ចម្លើយសារភាពរបស់ជនជាប់ចោទថាខ្លួនបានរក្សាទុក និងប្រើប្រាស់ថ្នាំញៀនគឺជាភស្តុតាងអាចឲ្យតុលាការពិចារណាបាន ចំពោះចម្លើយបដិសេធថាខ្លួនមិនធ្លាប់ជួញដូរគ្រឿងញៀនមិនអាចឲ្យតុលាការពិចារណាបានឡើយ ព្រោះថា ឈ្មោះ [redacted] ជឿន ធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ [redacted] គង្គារ បានចំនួនបីដងយកទៅប្រើប្រាស់។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ជឿន នាពេលសវនាការ បានឆ្លើយថា ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រហែល០១មួយឆ្នាំមកហើយ ប្រើខានប្រើខាន តែខ្លួនមិនដែលបានលក់ដូរថ្នាំញៀននោះទេ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀននេះតាមរយៈមិត្តភក្តិជាអ្នកបបួល ខ្លួនក៏សាកនិងញៀនតែម្តង។ ខ្លួនធ្លាប់ទិញថ្នាំញៀននេះពីឈ្មោះ [redacted] គង្គារ ចំនួន០៣លើក ដោយលើកទី១.ចំនួន០៣ម៉ឺនរៀល, លើកទី២. ចំនួន០៥ម៉ឺនរៀល និងលើកទី៣.ចំនួន០៦ម៉ឺនរៀល និងធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] វុត្ថា ដែលជាប៉ូលិសប្រាសាទព្រះវិហារ ចំនួន០២លើក ដោយលើកទី១.ចំនួន០៤ម៉ឺនរៀល និងលើកទី២. ចំនួន០៥ម៉ឺនរៀល ដោយចូលលុយគ្នាជាមួយមិត្តភក្តិ ទិញយកមកប្រើប្រាស់រួមគ្នា ខ្លួនមិនដែលបានលក់ដូរថ្នាំញៀននោះទេ។ តាំងពីអំឡុងពេលដែលខ្លួនបានដឹងថាគេចាប់ខ្លួនឈ្មោះទាំងពីរនាក់ខាងលើ ខ្លួនក៏ចាប់ផ្តើមផ្តាច់ខ្លួនឈប់ជក់ថ្នាំញៀនតទៅទៀតមកដល់បច្ចុប្បន្ននេះ។ ចម្លើយសារភាពរបស់ជនជាប់ចោទគឺជាភស្តុតាងអាចឲ្យតុលាការពិចារណាបាន។

-កំណត់ហេតុស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ស៊ុនលី បានឆ្លើយថា ខ្លួនចេះប្រើប្រាស់ថ្នាំញៀននេះដោយខ្លួនឯងដោយសារពិបាកចិត្ត ខ្លួនក៏សាកប្រើប្រាស់ថ្នាំញៀន និងញៀនតែម្តង។ ខ្លួនធ្លាប់ទិញថ្នាំញៀននេះពីឈ្មោះ [redacted] វុត្ថា ដែលជាប៉ូលិសប្រាសាទព្រះវិហារ ចំនួន០៣លើក ដោយលើកទី១.ចំនួន០៣ម៉ឺនរៀល, លើកទី២.ចំនួន០៤ម៉ឺនរៀល និងលើកទី៣.ចំនួន០៣ម៉ឺនរៀល យកមកប្រើប្រាស់តែម្នាក់ឯង។ ខ្លួនស្គាល់ឈ្មោះ [redacted] វុត្ថា នេះតាមរយៈមិត្តភក្តិឈ្មោះ [redacted] ជឿន កន្លងមកខ្លួនក៏មិនធ្លាប់ទិញថ្នាំញៀនពីអ្នកណាទៀតផ្សេងទៀតដែរ ខ្លួនមិនដែលបានលក់ដូរថ្នាំញៀននោះទេ។ តាំងពីអំឡុងពេលដែលខ្លួនបានដឹងថាគេចាប់ខ្លួនឈ្មោះទាំងពីរនាក់ខាងលើ ខ្លួនក៏ចាប់ផ្តើមផ្តាច់ខ្លួនឈប់ជក់ថ្នាំញៀនតទៅទៀតមកដល់បច្ចុប្បន្ននេះ ម្យ៉ាងខ្លួនក៏មិនចង់ឲ្យម៉ាក់ពិបាកចិត្តដោយសារខ្លួនតទៅទៀតដែរ។ ចម្លើយសារភាពរបស់ជនជាប់ចោទគឺជាភស្តុតាងអាចឲ្យតុលាការពិចារណាបាន។

-កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] ស្រីនាង បានឆ្លើយថា កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង៦ល្ងាច ប្តីរបស់ខ្លួនឈ្មោះ [redacted] វុត្ថា បានជិះម៉ូតូមកយកខ្លួនពីផ្ទះសំណាក់សោកណ្ណ រចនា ដើម្បីឡើងទៅលើភ្នំវិញ ដោយជិះម៉ូតូតាមផ្លូវកងពលតូចលេខ៨ ពេលជិះហួសសាលារៀនបន្តិច ក៏ឃើញមានកម្លាំងទាហ៊ាន និងនគរបាលចេញមកធ្វើការឃាត់ពួកខ្លួន និងឆែកឆេររកឃើញគ្រឿងញៀនចំនួន៥កញ្ចប់ នៅលើខ្លួនប្តីរបស់ខ្លួនឈ្មោះ [redacted] វុត្ថា ហើយក៏បញ្ជូនពួកខ្លួនទៅកាន់អធិការដ្ឋាននគរបាលស្រុកជាំក្សាន្ត ដើម្បីសាកសួរបន្ត។ ខ្លួនមិនបានដឹងថាគ្រឿងញៀននោះគាត់ទិញពីអ្នកណាមកទេ ហើយខ្លួនក៏មិនធ្លាប់ប្រើប្រាស់ និងរកស៊ីជួញដូរគ្រឿងញៀនដែរ សមត្ថកិច្ចបាន

ពិនិត្យទឹកនោមរបស់ខ្លួនរកសារធាតុញៀន ជាលទ្ធិផលអវិជ្ជមាន។ ចម្លើយសាក្សីគឺជាភស្តុតាងអាចឲ្យតុលាការពិចារណាបាន។

-កំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះវិហារ មានដូចជា៖

-វត្ថុតាងក្រាមពណ៌សថ្លាមេតំហ្វេតាមីន ទំងន់២,៦៧ក្រាម (ពីរក្បៀសហុកសិបប្រាំពីរក្រាម) ដកហូតពីឈ្មោះ[redacted]គង្ការ ។

-វត្ថុតាងក្រាមពណ៌សថ្លាប្រភេទមេតំហ្វេតាមីន ទម្ងន់៤៨,៥៨(សែសិបប្រាំបីក្បៀសហាសិបប្រាំបីក្រាម) ដកហូតពីឈ្មោះ[redacted] វុត្ថា ។

-សម្ភារៈតេស្តសារធាតុញៀនចំនួន៣, ថង់ពណ៌សចំនួន០១ និងដែកកេះចំនួន១ គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល។

-ម៉ូតូចំនួន០២គ្រឿង ១គ្រឿងម៉ាក់អ៊ិចស៊ិចទ័រ ពណ៌ស គ្មានផ្លាកលេខ(ចាស់) របស់ឈ្មោះ [redacted] គង្ការ និង១គ្រឿងទៀតម៉ាក់ អ៊ិចស៊ិចទ័រ ពណ៌ខៀវ បិទស្កុតពណ៌ខ្មៅ គ្មានផ្លាកលេខ(ចាស់) របស់ឈ្មោះ[redacted] វុត្ថា ។

-ទូរស័ព្ទម៉ាកអាយហ្វូន7Pluse១គ្រឿង ពណ៌ខ្មៅ(ចាស់), ទូរស័ព្ទម៉ាកVIVO១គ្រឿង ពណ៌ខ្មៅ ស្នាមបែកអេក្រង់(ចាស់) ទូរស័ព្ទម៉ាកVIVO ពណ៌ផ្ទៃមេឃ ស្នាមបែកអេក្រង់(ចាស់) និងទូរស័ព្ទម៉ាក Fealme ពណ៌ទឹកប៊ិច(ចាស់) គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

-យោងតាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣១៩២២/២១ ម.ព.អ.ជ.ប.គ.៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺជាសារធាតុញៀនជាប្រភេទមេតំហ្វេតាមីន ដែលមានបរិមាណគិតជាភាគរយនៃទម្ងន់គឺ៧៧.០២% បើគិតជាចំនួនក្រាម គឺ៤៨,៥៨ក្រាម គុណនឹង៧៧,០២ ចែកនឹង១០០ ស្មើនឹង៣៧.៤១៦ក្រាម គឺស្របទៅនឹងមាត្រា៤០ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជារបស់ឈ្មោះ[redacted] វុត្ថា ។

-យោងតាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣១៩២១/២១ ម.ព.អ.ជ.ប.គ.៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ដែលមានបរិមាណគិតជាភាគរយនៃទម្ងន់គឺ៧៧.០២% បើគិតជាចំនួនក្រាម គឺ២,៦៧ក្រាម គុណនឹង៧៧,០២ ចែកនឹង១០០ ស្មើនឹង២,០៥៦ក្រាម គឺស្របទៅនឹងមាត្រា៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជារបស់ឈ្មោះ[redacted]គង្ការ ។

-កំណត់ហេតុធ្វើតេស្តទឹកនោមលេខ០៣/០៦ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់ផ្នែកប្រឆាំងគ្រឿងញៀន នៃអធិការដ្ឋាននគរស្រុកជាំក្សាន្ត បានធ្វើតេសទឹកនោមទៅលើជនជាប់ចោទឈ្មោះ[redacted]គង្ការ និងឈ្មោះ [redacted] វុត្ថា លទ្ធផលវិជ្ជមាន បង្ហាញឲ្យឃើញថា ជនជាប់ចោទបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

-វិភាគលើចម្លើយរបស់ជនជាប់ចោទ ,ចម្លើយសាក្សី របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ,ការស៊ើបអង្កេតនៅដំណាក់កាលអយ្យការ និងការស៊ើបសួរនៅដំណាក់កាលចៅក្រមស៊ើបសួរ គឺជាភស្តុតាងមានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថា៖ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៥និង៣០នាទី នៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៅចំណុចជិតក្លោងទ្វារសណ្ឋាគារព្រះវិហារពេជ្រ មានកម្លាំងសមត្ថកិច្ច...យុំ

ព្រះវិហារ ថ្ងៃទី... ខែ... ឆ្នាំ២០...

កន្ទួត បានធ្វើការឃាត់ជនសង្ស័យមួយនាក់ឈ្មោះ [redacted] គង្គារ ភេទស្រី អាយុ២២ឆ្នាំ រួមជាមួយថ្នាំញៀនមួយកញ្ចប់ប្រភេទមេតំហ្វេតាមីន ទម្ងន់២,៦៧ក្រាម ហើយធ្វើតេស្តនៅក្នុងទឹកនោមរបស់របស់ឈ្មោះ [redacted] គង្គារ លទ្ធផលវិជ្ជមាន ។ ឈ្មោះ [redacted] គង្គារ បានឆ្លើយថាថ្នាំញៀននោះខ្លួន ទិញពីឈ្មោះ [redacted] វុត្ថា តម្លៃ១០ម៉ឺនរៀល ហើយនៅថ្ងៃដដែលនៅវេលាម៉ោង១៩និង២០នាទី សមត្ថកិច្ចបានស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យម្នាក់ទៀតឈ្មោះ [redacted] វុត្ថា រួមទាំងដកហូតបានថ្នាំញៀនប្រភេទមេតំហ្វេតាមីន ទម្ងន់៤៨,៥៨ក្រាម នៅភូមិចំបក់សែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ឈ្មោះ [redacted] វុត្ថា បានឆ្លើយថា គ្រឿងញៀននោះខ្លួនបានទិញពីឈ្មោះ ណាក់ ក្នុងតម្លៃ២(ពីរ)លានរៀល កន្លងមកខ្លួនបានទិញពីឈ្មោះ ណាក់ នេះ បានចំនួន០៤ដង និងបានលក់ចែកចាយឱ្យឈ្មោះ [redacted] ស៊ុនលី, ឈ្មោះ [redacted] ជឿន, ឈ្មោះ ហួរ និងឈ្មោះ [redacted] គង្គារ ប្រាកដមែន។

-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ២៨ឆ្នាំ គឺជាការប្រព្រឹត្តិដោយចេតនានូវបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ ,៥ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] គង្គារ ភេទស្រី អាយុ២១ឆ្នាំ គឺជាការប្រព្រឹត្តិដោយចេតនានូវបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន ហៅ អាជឿន ភេទប្រុស កើតថ្ងៃទី០៤,០៨.២០០៦ និងឈ្មោះ [redacted] ស៊ុនលី ហៅ អាលី ភេទប្រុស កើតថ្ងៃទី១៧.០៧.២០០០ គឺជាការប្រព្រឹត្តិដោយចេតនានូវបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើៈ

១/ឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ២៨ឆ្នាំ ពីបទៈ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តិនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ ,៥ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ។

២/ឈ្មោះ [redacted] គង្គារ ភេទស្រី អាយុ២១ឆ្នាំ ពីបទៈ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តិនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣/ឈ្មោះ [redacted] ជឿន ហៅ អាជឿន ភេទប្រុស កើតថ្ងៃទី០៤.០៨.២០០៦ និងឈ្មោះ [redacted] ស៊ុនលី ហៅអាលី ភេទប្រុស កើតថ្ងៃទី១៧.០៧.២០០០ ពីបទៈ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តិនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការ សន្និដ្ឋានពីកស្តុតាងដាក់បន្ទុក និងពិរុទ្ធភាព សុំតម្កល់ការចោទប្រកាន់របស់ខ្លួន និងសូមអោយតុលាការពិនិត្យសម្រេចតាមច្បាប់។



Scanned with CamScanner

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ នាពេលសវនាការ សន្និដ្ឋានថា កូនក្តីខ្លួន ឈ្មោះ [redacted] វុត្ថា និងឈ្មោះ [redacted] ជឿន បានសារភាពនូវទង្វើរបស់ខ្លួនដែលបានប្រព្រឹត្ត ព្រមទាំងអង្គហេតុដែលបានចោទប្រកាន់ និងទទួលស្គាល់វត្ថុតាងដែលបានដកហូត ហើយបានសម្តែងនូវការសោកស្តាយចង់កែប្រែខ្លួនឡើងវិញឈប់ប្រព្រឹត្តទៀតហើយ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។ ចំណែកឈ្មោះ [redacted] គង្គារ មានកូនតូចទើបតែអាយុ២ឆ្នាំ យកទៅផ្ញើបងប្រុសជួយមើលជំនួស ជាស្រ្តីមេម៉ាយទាំងក្មេងត្រូវទទួលបន្ទុកមើលថែកូន ហេតុនេះសូមឲ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយសម្រាលទោសដោយអនុគ្រោះផង។

-សំដីចុងក្រោយរបស់ជនជាប់ចោទ៖ ឈ្មោះ [redacted] វុត្ថា និងឈ្មោះ [redacted] ជឿន សូមឲ្យតុលាការបន្ធូបបន្ថយទោសផង ចំណែកឈ្មោះ [redacted] គង្គារ សុំអោយតុលាការដោះលែងខ្លួន ឆាប់បានត្រឡប់ទៅចិញ្ចឹមមើលថែកូនដែលមានអាយុទើបតែ២ឆ្នាំ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១/-ផ្តន្ទាទោសលើ៖

ក.ឈ្មោះ [redacted] វុត្ថា ភេទប្រុស អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ តែត្រូវអនុវត្តទោសពន្ធនាគារកំណត់២(ពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ ទោសនៅសល់ត្រូវអនុវត្តព្យួរទោសធម្មតា និងពិន័យជាប្រាក់ចំនួន១០.០០០.០០០(ដប់លាន)រៀល ពីបទ៖ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តិនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤, ៥ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ តាមមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted] គង្គារ ភេទស្រី អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល២(ពីរ)ឆ្នាំ តែត្រូវអនុវត្តទោសពន្ធនាគារកំណត់១(មួយ)ឆ្នាំ ទោសនៅសល់ត្រូវអនុវត្តព្យួរទោសធម្មតា ពីបទ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តិនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ តាមមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ

គ.ឈ្មោះ [redacted] ជឿន ហៅ អាជឿន ភេទប្រុស កើតថ្ងៃទី០៤.០៨.២០០៦ និងឈ្មោះ [redacted] ស៊ុនលី ហៅអាលី ភេទប្រុស កើតថ្ងៃទី១៧.០៧.២០០០ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់៣(បី)ខែ តែត្រូវអនុវត្តព្យួរទោសធម្មតា និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន៤០០.០០០(បួនសែន)រៀល ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តិនៅភូមិស្រអែមជើង ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣/-វត្ថុតាងរួមមាន៖

ក.ម្សៅក្រាមពណ៌សថ្លាមេតំហ្វេតាមីន ទម្ងន់២,៦៧ក្រាម(ពីរក្បៀសហុកសិបប្រាំពីរក្រាម) ដកហូតពីឈ្មោះ [redacted] គង្គារ និងម្សៅក្រាមពណ៌សថ្លាប្រភេទមេតំហ្វេតាមីន ទម្ងន់ [illegible]

ព្រះវិហារ ថ្ងៃទី ... ឆ្នាំ២០...

ក្រឡាបញ្ជី

[redacted]

ប្រាំបីក្បៀសហាសិបប្រាំបីក្រាម) ដកហូតពីឈ្មោះ [redacted] វុត្ថា និងសម្ភារៈតេស្តសារធាតុញៀនចំនួន ០៣, ថង់ពណ៌សចំនួន០១ និងដែកកេះ ចំនួន០១ **ត្រូវរឹបអូសបំផ្លាញចោល។**

ខ.ម៉ូតូចំនួន០២គ្រឿង ១គ្រឿងម៉ាក់អ៊ិចស៊ិចទ័រ ពណ៌ស គ្មានផ្លាកលេខ(ចាស់) និង ១គ្រឿងទៀតម៉ាក់ អ៊ិចស៊ិចទ័រ ពណ៌ខៀវ បិទស្កុតពណ៌ខ្មៅ គ្មានផ្លាកលេខ(ចាស់) និងទូរស័ព្ទម៉ាកអាយហ្វូន 7Pluse ១គ្រឿង ពណ៌ខ្មៅ(ចាស់),ទូរស័ព្ទម៉ាកVIVO ១គ្រឿង ពណ៌ខ្មៅ ស្នាមបែកអេក្រង់(ចាស់) ទូរស័ព្ទម៉ាកVIVO ពណ៌ផ្ទៃមេឃ ស្នាមបែកអេក្រង់(ចាស់) និងទូរស័ព្ទម៉ាកFealme ពណ៌ទឹក ប៊ិច (ចាស់) **ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។**

៤/-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ចំពោះមុខឈ្មោះ [redacted] វុត្ថា ,ឈ្មោះ [redacted] គង្គារ និងឈ្មោះ [redacted] ជឿន កំបាំងមុខឈ្មោះ [redacted] ស៊ុនលី ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ព្រះវិហារ,ថ្ងៃទី១២ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner